វ៉ុល១ លេខទី៦ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩

# ហេតុអ្វីអក្ខរកម្មឌីជីថលមានសារសំខាន់?

តាន់ មុន្នីវិសាល*

ការផ្លាស់ប្តូរបែបឌីជីថល បានក្លាយជាទិសដៅសំខាន់មួយនៃគោលនយោបាយក្នុងប្រទេសជាច្រើន ខណៈពេលដែលប្រទេសទាំងអស់នោះបាន និងកំពុងខិតខំសម្របខ្លួនទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤។ ដោយសារតែមានការអភិវឌ្ឍ និងរីកលូតលាស់នៃបច្ចេកវិទ្យាឌីជីថលលើគ្រប់វិស័យ មនុស្សស្ទើរតែគ្រប់រូបបាន និងកំពុងប្រើប្រាស់ឧបករណ៍ឌីជីថលមានដូចជា ទូរស័ព្ទដៃ ឧបករណ៍វៃឆ្លាត និងឧបករណ៍ទំនើបៗជាច្រើនទៀត ដែលជួយបង្កើនគុណភាពជីវិត ព្រមទាំងបទពិសោធន៍នៃការប្រកបការងារវិជ្ជាជីវៈជាដើម។ ខណៈពេលដែលយើងអាចស្វែងរកឧបករណ៍ និងបច្ចេកវិទ្យាទំនើបទាំងនោះបានយ៉ាងងាយស្រួល វាតម្រូវឲ្យយើងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទំនួលខុសត្រូវ។ លើសពីនេះទៀត នៅពេលដែលព័ត៌មានជាច្រើនរីកសុសសាយនៅលើប្រព័ន្ធអ៊ីនធឺណិត វាត្រូវទាមទារឲ្យយើងចេះពិចារណាលើភាពត្រឹមត្រូវ និងច្បាស់លាស់នៃព័ត៌មានទាំងនោះ ដើម្បីចៀសវាងការយល់ខុស និងភាន់ច្រឡំនានា។ មូលហេតុទាំងនេះ ធ្វើឲ្យអក្ខរកម្មឌីជីថលមានសារសំខាន់យ៉ាងខ្លាំងសម្រាប់ការរស់នៅក្នុងបរិស្ថានឌីជីថល ក៏ដូចជានៅក្នុងយុគសម័យព័ត៌មាន។

## ❖ និយមន័យអក្ខរកម្មឌីជីថល

និយមន័យអក្ខរកម្មឌីជីថលមានច្រើនបែបច្រើនយ៉ាង ហើយវាផ្លាស់ប្តូរទៅតាមបរិបទរបស់វា និងមានការបកស្រាយផ្សេងៗគ្នាទៅតាមបញ្ញវន្តម្នាក់ៗ។ លោក Gilster បានកំណត់និយមន័យនៃពាក្យ អក្ខរកម្មឌីជីថល ថាជាសមត្ថភាពក្នុងការយល់ដឹង និងប្រើប្រាស់ព័ត៌មានពីប្រភពឌីជីថល។ និយមន័យនេះ បើនិយាយឲ្យសាមញ្ញ គឺជាការបកស្រាយបន្ថែមពីលើនិយមន័យដើមនៃពាក្យអក្ខរកម្ម ដែលមានន័យថា បុគ្គលម្នាក់ៗអាចអាន សរសេរ និងទទួលយកព័ត៌មាន ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងទម្រង់ឌីជីថល។ និយមន័យមួយទៀត ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺគេត្រូវរាប់បញ្ចូលទាំងសមត្ថភាពគិត និងវាយតម្លៃក្នុងអក្ខរកម្មឌីជីថល។ ក្នុងនិយមន័យនេះ អក្ខរកម្មឌីជីថល គឺជាសមត្ថភាពក្នុងការស្វែងរក ប្រើប្រាស់ បង្កើត និងផ្សព្វផ្សាយខ្លឹមសារឌីជីថល (Paul, Kerkshoff & Spires, 2017)។ ការស្វែងរក និងប្រើប្រាស់ខ្លឹមសារឌីជីថលនៅលើប្រព័ន្ធអ៊ីនធឺណិត តម្រូវឲ្យយើងចេះស្វែងរក និងវាយតម្លៃភាពត្រឹមត្រូវ និងភាពពាក់ព័ន្ធរបស់ព័ត៌មានដែលយើងចង់បាន។ ចំណែកឯការបង្កើតខ្លឹមសារឌីជីថល គឺអាចធ្វើបានតាមរយៈទម្រង់នៃវិធីសាស្ត្រមួយចំនួន ដូចជាការសរសេរសារ និងអត្ថបទនៅលើឧបករណ៍ឌីជីថល និងការបង្កើតខ្លឹមសារវីដេអូ ដោយប្រើប្រាស់កម្មវិធីកាត់តវីដេអូជាដើម។ ដោយពេលបច្ចុប្បន្ននេះ ការបង្កើតខ្លឹមសារឌីជីថលអាចធ្វើឡើងបានដោយងាយស្រួល សមត្ថភាពក្នុងការផ្សព្វផ្សាយខ្លឹមសារតាមប្រព័ន្ធអនឡាញ និងបណ្តាញទំនាក់ទំនងសង្គមដូចជា Facebook និង Twitter ក៏បានក្លាយជាផ្នែកដ៏សំខាន់មួយនៃអក្ខរកម្មឌីជីថល។ គណៈកម្មការអឺរ៉ុប សភាអឺរ៉ុប និងក្រុមអ្នកសិក្សាស្រាវជ្រាវអឺរ៉ុប បានចាត់ទុកជំនាញមូលដ្ឋានមួយចំនួននៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ថាជាផ្នែក

*__លោក តាន់ មុន្នីវិសាល__ ជាអ្នកសម្របសម្រួលកម្មវិធី នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

មួយចាំបាច់សម្រាប់អក្ខរកម្មឌីជីថល ហើយបានប្រើប្រាស់ពាក្យ អក្ខរកម្មឌីជីថល លាយឡំគ្នាជាមួយពាក្យ សមត្ថភាពឌីជីថល ជំនាញឌីជីថល និង e-Competence (Department of eLearning, n.d.)។ នៅក្នុងក្របខណ្ឌសមត្ថភាពឌីជីថលដែលបានបង្កើតឡើងដោយស្ថាប័នសហភាពអឺរ៉ុបខាងលើ ដើម្បីស្វែងរកការស្រុះស្រួលមតិលើការកំណត់អត្តសញ្ញាណសមត្ថភាពឌីជីថល គេបានបែងចែកផ្នែកចំនួន៥សំខាន់សម្រាប់ក្តោបន័យរបស់សមត្ថភាពឌីជីថល ដោយរួមមាន៖ ១) ព័ត៌មាន - Information៖ ការស្វែងរកទីតាំង កំណត់ និងវិភាគព័ត៌មាន, ២) សារគមនាគមន៍ - Communication៖ ការផ្សព្វផ្សាយ និងចែករំលែកខ្លឹមសារឌីជីថលដោយប្រើឧបករណ៍អនឡាញ, ៣) ការបង្កើតខ្លឹមសារ - Content Creation៖ ការបង្កើត កែសម្រួលខ្លឹមសារ និងព័ត៌មាន ជាពាក្យ រូបភាព និងវីដេអូ ក៏ដូចជាការដោះស្រាយ និងអនុវត្តតាមកម្មសិទ្ធិបញ្ញា និងអាជ្ញាប័ណ្ណក្នុងការប្រើប្រាស់ព័ត៌មានពីប្រភពដើម, ៤) ការការពារសុវត្ថិភាព - Safety៖ ការការពារទិន្នន័យផ្ទាល់ខ្លួន និងអត្តសញ្ញាណឌីជីថល ដោយមានវិធានការត្រឹមត្រូវ និងសមស្រប, និង ៥) ការដោះស្រាយបញ្ហា - Problem Solving៖ ការកំណត់តម្រូវការទាក់ទងនឹងឌីជីថល និងធ្វើការសម្រេចចិត្តក្នុងការដោះស្រាយបញ្ហា ដោយប្រើប្រាស់ឧបករណ៍ និងមធ្យោបាយឌីជីថលដែលសមស្រប។

**ក្របខណ្ឌសមត្ថភាពឌីជីថល**




*ប្រភព៖ EU Delegation to the Republic of Serbia*[1]

[1] សម្រាប់ព័ត៌មានបន្ថែម សូមមើល EU Delegation to the Republic of Serbia. (2018, January 17). *New measures to boost key and digital competences, as well as the European dimension of education.* Retrieved from https://europa.rs/new-measures-to-boost-key-and-digital-competences-as-well-as-the-european-dimension-of-education/?lang=en

### ❖ តួនាទីអក្ខរកម្មឌីជីថល

ចំណេះដឹង គឺជាផ្នែកសំខាន់មួយក្នុងការអភិវឌ្ឍធនធានមនុស្ស និងសង្គមទាំងមូល។ ក្នុងន័យដូចគ្នានេះដែរ អក្ខរកម្មឌីជីថល ក៏ដើរតួនាទីយ៉ាងសំខាន់ដូចគ្នានៅក្នុងការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលម្នាក់ៗ ជាពិសេសក្នុងសង្គមឌីជីថល។ ជាក់ស្តែង អក្ខរកម្មឌីជីថល អាចជួយឲ្យយុវជនទាញយកអត្ថប្រយោជន៍ពីធនធានឌីជីថល ដើម្បីសិក្សារៀនសូត្រ និងលើកកម្ពស់ការអភិវឌ្ឍខ្លួន។ ដរាបណា ពួកគេអាចមានលទ្ធភាពប្រើប្រាស់ឧបករណ៍ឌីជីថល និងមានជំនាញបច្ចេកវិទ្យាជាមូលដ្ឋាន ការសិក្សារៀនសូត្រ និងស្វែងរកឯកសារស្រាវជ្រាវ អាចធ្វើបានយ៉ាងងាយស្រួល តាមរយៈមធ្យោបាយឌីជីថលផ្សេងៗ រួមមាន បណ្ណាល័យអនឡាញ (Online Libraries) ការបង្រៀនតាមវីដេអូអនឡាញ (Video Conferences) និងថ្នាក់រៀននិម្មិត (Virtual Classrooms) ជាដើម។ លើសពីនេះ ជំនាញបច្ចេកវិទ្យាមូលដ្ឋាន ដែលបុគ្គលម្នាក់ៗបានអភិវឌ្ឍក្នុងដំណាក់កាលសិក្សាអប់រំ នឹងផ្តល់អត្ថប្រយោជន៍ជាច្រើនថែមទៀត ដល់អាជីពវិជ្ជាជីវៈ និងការងាររបស់ពួកគេនាពេលអនាគត។ ក្នុងនោះ សូម្បីតែសមត្ថភាពក្នុងការបង្កើតឯកសារ ឬតារាងទិន្នន័យ តាមរយៈកម្មវិធី Microsoft Office ដូចជា កម្មវិធី Word និង Excel ក៏ត្រូវបានចាត់ទុកជាជំនាញបច្ចេកវិទ្យាដែលមានតម្រូវការផងដែរ (Angeles, 2014)។

តួនាទីផ្សេងទៀតរបស់អក្ខរកម្មឌីជីថល គឺការចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។ ជាក់ស្តែង សកម្មភាពសេដ្ឋកិច្ចតាមបែបប្រពៃណី កំពុងត្រូវបានផ្លាស់ប្តូរ និងជំនួសដោយទម្រង់ថ្មី ដែលពឹងផ្អែកទាំងស្រុងទៅលើអន្តរទំនាក់ទំនងរវាងបច្ចេកវិទ្យា ទិន្នន័យ ធុរកិច្ច និងមនុស្ស (Deloitte, n.d.)។ លើសពីនេះ សហប្រតិបត្តិការរវាងមនុស្ស ស្ថាប័ន និងម៉ាស៊ីន នឹងផ្សារភ្ជាប់គ្នាកាន់តែខ្លាំងឡើង ដែលគេហៅថា បណ្តាញទំនាក់ទំនងជាប្រចាំលើប្រព័ន្ធអ៊ីនធឺណិត (Hyper-connectivity) ដោយសារការប្រើប្រាស់អ៊ីនធឺណិត និង បច្ចេកវិទ្យាផ្សេងទៀត ដូចជាឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត (Internet of Things) និងប្រព័ន្ធនិម្មិត (Visual System)។ ដោយសារភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាទំនើបពីបដិវត្តន៍ឧស្សាហកម្មកន្លងមក ប្រជាជនត្រូវការជាចាំបាច់នូវសមត្ថភាពផ្នែកឌីជីថលឲ្យបានគ្រប់គ្រាន់ ក្នុងប្រតិបត្តិការប្រព័ន្ធអេឡិចត្រូនិក ដូចជា ធុរកិច្ចឌីជីថល និងសកម្មភាពជំនួញឌីជីថលផ្សេងៗទៀត ដើម្បីចូលរួមក្នុងប្រពន្ធសេដ្ឋកិច្ចឌីជីថល។ យ៉ាងហោចណាស់ ពួកគេត្រូវមានចំណេះដឹងជាមូលដ្ឋានទាក់ទងនឹងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរួមមាន ការគ្រប់គ្រងទិន្នន័យ (Data Management) ដំណើរការនៃពាក្យ (Word Processing) និងការស្រាវជ្រាវលើប្រព័ន្ធអ៊ីនធឺណិត (Online Research) ដើម្បីយល់ និងប្រើប្រាស់បច្ចេកវិទ្យាទាំងនោះឲ្យអស់ពីលទ្ធភាព។

ស្រដៀងគ្នានេះដែរ ការអភិវឌ្ឍសង្គមឌីជីថលមួយតម្រូវឲ្យមានការចូលរួមពីប្រជាពលរដ្ឋ ដែលមានចំណេះដឹងផ្នែកឌីជីថល។ តាមការសិក្សា អេស្តូនី ត្រូវបានគេចាត់ទុកជាប្រទេសឈានមុខគេក្នុងចំណោមប្រទេស កំពុងប្រែក្លាយជាសង្គមឌីជីថល ដែលបានធ្វើការផ្លាស់ប្តូរបែបឌីជីថលស្ទើរតែគ្រប់វិស័យក្នុងសង្គម។ ឧទាហរណ៍៖ រដ្ឋាភិបាលប្រទេសអេស្តូនីបានចាប់ផ្តើមណែនាំប្រព័ន្ធអភិបាលកិច្ចអេឡិចត្រូនិក ដល់ប្រជាជនតាំងពីឆ្នាំ១៩៩៧ និងបានបន្តវិនិយោគលើដំណោះស្រាយអេឡិចត្រូនិក (e-Solution) ជាច្រើនទៀត មានដូចជាពន្ធអេឡិចត្រូនិក (eTax), អត្តសញ្ញាណឌីជីថល (Digital ID), ការបោះឆ្នោតអនឡាញ (i-Voting), បច្ចេកវិទ្យា Block-chain និងអ្នកតាំងលំនៅស្ថានអេឡិចត្រូនិក (e-Resident) (e-Estonia, n.d.)។ កត្តារួមចំណែកដ៏ធំបំផុតមួយក្នុងភាពជោគជ័យនៃការផ្លាស់ប្តូរឌីជីថលរបស់អេស្តូនី គឺពឹងផ្អែកលើការលើកកម្ពស់អក្ខរកម្មឌីជីថលក្នុងវិស័យអប់រំ។ ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៩០ សាលារៀនទាំងអស់នៅអេស្តូនី មានប្រព័ន្ធអ៊ីនធឺណិតប្រើប្រាស់គ្រប់គ្រាន់ ហើយអក្ខរកម្មកុំព្យូទ័របានក្លាយជាអាទិភាពមួយក្នុងវិស័យអប់រំក្នុងប្រទេស (Mansel, 2013)។ ជាលទ្ធផល អត្រាជំនាញឌីជីថលមូលដ្ឋានរបស់ប្រជាជនអេស្តូនី មានកម្រិតខ្ពស់ជាងអត្រាជាមធ្យមក្នុង សហភាពអឺរ៉ុបទាំង២៨ ប្រទេស (European Commission, 2019)។

## ❖ អក្ខរកម្មឌីជីថលសម្រាប់ការផ្លាស់ប្តូរបែបឌីជីថលក្នុងតំបន់ និងបរិបទកម្ពុជា

នាពេលបច្ចុប្បន្ននេះ ការផ្លាស់ប្តូរបែបឌីជីថល ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំង ខណៈពេលដែលសេដ្ឋកិច្ចសាកលកំពុងស្ថិតក្រោមឥទ្ធិពលនៃបច្ចេកវិទ្យាឌីជីថល និងការមកដល់នៃបដិវត្តន៍ឧស្សាហកម្មទី៤។ ជាក់ស្តែង តំបន់អាស៊ានជាពិសេស បានខិតខំប្រឹងប្រែងខ្លាំងណាស់ ក្នុងការផ្លាស់ប្តូរបែបឌីជីថលក្នុងតំបន់ ដើម្បីបង្កើនកំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរៀងៗខ្លួន។ ក្នុងពេលដែលប្រទេសថៃ ជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ២០១៩ អាស៊ានមានបំណងលើកកម្ពស់សមត្ថភាពរបស់សមាគមនេះ ដោយចាប់យកប្រយោជន៍ពីបដិវត្តន៍ឧស្សាហកម្មទី៤។ ដើម្បីសម្រេចនូវមហិច្ឆតានេះ ប្រទេសថៃក្នុងនាមជាម្ចាស់ផ្ទះ បានដាក់ស្នើអាទិភាពអភិវឌ្ឍសេដ្ឋកិច្ចចំនួន១២ ក្នុងនោះមានសំណើចំនួន៥ ទាក់ទងនឹងឧស្សាហកម្ម ៤.០ រួមមានៈ ទី១) សេចក្តីប្រកាសស្តីពីការផ្លាស់ប្តូរឧស្សាហកម្មទៅកាន់ឧស្សាហកម្ម៤.០, ទី២) ផែនការសកម្មភាពក្នុងក្របខណ្ឌសមាហរណកម្មឌីជីថល, ទី៣) ផែនការយុទ្ធសាស្ត្រនវានុវត្តន៍អាស៊ាន, ទី៤) គោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍកម្លាំងឌីជីថលជំនាញ, និងទី៥) គោលការណ៍ណែនាំសម្រាប់ធ្វើឌីជីថលូបនីយកម្មអាជីវកម្មក្នុងតំបន់អាស៊ាន (Sagar, 2019)។

ទោះបីជាមានសក្តានុពលធំធេងសម្រាប់ការផ្លាស់ប្តូរឌីជីថលក៏ដោយ អាស៊ាននៅតែប្រឈមនឹងបញ្ហាជាច្រើនទាក់ទងនឹងឌីជីថលូបនីយកម្ម និងបច្ចេកវិទ្យាទំនើប។ បញ្ហាចម្បងជាងគេ គឺគម្លាតឌីជីថលរវាងបណ្តាប្រទេសជាសមាជិកអាស៊ានទាំង១០។ ជាឧទាហរណ៍ៈ ក្នុងចំណោមអ្នកប្រើប្រាស់អ៊ីនធឺណិតចំនួន១០០នាក់ក្នុងតំបន់ សិង្ហបុរី ម៉ាឡេស៊ី និងព្រុយណេមានប្រជាជនប្រមាណពី៧០ ទៅ៨០នាក់ ខណៈដែលដង់ស៊ីតេអ្នកប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជា និងឡាវមានតិចជាង២០នាក់ប៉ុណ្ណោះ (Basu Das, 2018)។ លើសពីនេះ សិង្ហបុរី គឺជារដ្ឋសមាជិកអាស៊ានតែមួយគត់ដែលមានភាពលេចធ្លោលើផ្នែកសមត្ថភាពឌីជីថលូបនីយកម្ម និងការប្រកួតប្រជែងឌីជីថលដោយសិង្ហបុរី បានស្ថិតក្នុងចំណាត់ថ្នាក់កំពូលទាំង១០នៃសន្ទស្សន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់អង្គការសហប្រជាជាតិ និងស្ថិតក្នុងចំណាត់ថ្នាក់កំពូលទាំង២០ នៃចំណាត់ថ្នាក់សេដ្ឋកិច្ចឌីជីថលរបស់អង្គភាពព័ត៌មានសេដ្ឋកិច្ចវិទូ (the Economist Intelligence Unit Digital Economy Ranking) (Luo, 2016)។ ក្រៅពីនេះ សមាជិកអាស៊ានប្រឈមមុខជាមួយឧបសគ្គរួមមួយដែលកំពុងរារាំងដល់ការកសាងសេដ្ឋកិច្ចឌីជីថល គឺកង្វះខាតកម្លាំងការងារជំនាញដែលប៉ះពាល់យ៉ាងខ្លាំងដល់សមត្ថភាពប្រកួតប្រជែងរបស់អាស៊ានក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន(Basu Das, 2018)។

ស្រដៀងគ្នានេះ កម្រិតទាបនៃអក្ខរកម្មឌីជីថល ក្នុងចំណោមប្រជាពលរដ្ឋ ក៏ជាឧបសគ្គដល់សហគមន៍ឌីជីថលអាស៊ានផងដែរ។ នៅក្នុងសង្គមមួយដែលមានព័ត៌មានពេញលេញ និងប្រកបដោយបរិយាប័ន្ន ពលរដ្ឋត្រូវមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានព័ត៌មាន និងឱកាសនានា ដើម្បីចៀសវាងការបាត់បង់ផលប្រយោជន៍ ពីការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល។ ដើម្បីទាញយកប្រយោជន៍ពីប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងអ៊ីនធឺណិត ក៏ដូចជាការបង្កើតសង្គមឌីជីថលពេញលេញមួយអាស៊ាន គួរបន្តកសាង និងលើកកម្ពស់អក្ខរកម្មឌីជីថលរបស់ប្រជាជន ដោយដាក់បញ្ចូលធាតុផ្សំជាមូលដ្ឋានគ្រឹះទាំងបួននៃអក្ខរកម្មឌីជីថល រួមមានសមត្ថភាពជាមូលដ្ឋានក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថល, ជំនាញក្នុងការវាយតម្លៃភាពត្រឹមត្រូវរបស់ព័ត៌មានអនឡាញ, ភាពប្រុងប្រយ័ត្នក្នុងការជ្រើសរើសព័ត៌មានត្រឹមត្រូវក្នុងការចែករំលែកនៅលើប្រព័ន្ធអនឡាញ, និងការយល់ដឹងអំពីអាកប្បកិរិយាតាមអនឡាញដែលមានសុវត្ថិភាព។ ដូច្នេះ អក្ខរកម្មឌីជីថល គួរត្រូវបានផ្តល់អាទិភាពនៅក្នុងកម្មវិធីអប់រំ ដោយមានការចូលរួម និងគាំទ្រពីសំណាក់រដ្ឋាភិបាល និងវិស័យឯកជន ដើម្បីបំពាក់បំប៉នអក្ខរកម្មឌីជីថល និងសមត្ថភាពឌីជីថលដល់ប្រជាជន។

ទោះបីជានៅមានភាពទន់ខ្សោយផ្នែកអក្ខរកម្មឌីជីថល អាស៊ានបានបន្តកិច្ចខិតប្រឹងប្រែងរបស់ខ្លួនគួរឲ្យកត់សម្គាល់លើការពង្រឹងអក្ខរកម្មឌីជីថលនេះ។ ជាឧទាហរណ៍ៈ ក្រសួងសង្គម

និងសេដ្ឋកិច្ចឌីជីថលរបស់ប្រទេសថៃ បានអនុវត្តកម្មវិធីដែលមានឈ្មោះថា Net Pracharat ក្នុងគោលដៅផ្តល់វគ្គបណ្តុះបណ្តាលអំពីអក្ខរកម្មឌីជីថលដល់ប្រជាជនចំនួន៤លាននាក់ ដើម្បីលុបបំបាត់គម្លាតឌីជីថល និងធ្វើឲ្យប្រសើរឡើងនូវសមត្ថភាព ក្នុងការប្រកបធុរកិច្ចឌីជីថលនៅក្នុងសហគមន៍នៃប្រទេសថៃ (Tortermvasana, 2018)។ កម្មវិធីនេះក៏បានបំពាក់ប្រព័ន្ធ Wifi ដោយឥតគិតថ្លៃ និងហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតអត់ខ្សែ ដែលមានតម្លៃថោកទៅដល់ភូមិចំនួន ៤០០០០។ ដូចគ្នានេះ រដ្ឋាភិបាលសិង្ហបុរីបានសហការជាមួយក្រុមហ៊ុន Facebook ដើម្បីដាក់ចេញគំនិតផ្តួចផ្តើមអក្ខរកម្មឌីជីថលមានឈ្មោះថា "យើងគិតបែបឌីជីថល (We Think Digital)" ក្នុងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ចំណេះដឹងផ្នែកឌីជីថលដល់ប្រជាជនរបស់ខ្លួន (Channel News Asia, 2019)។ កម្មវិធីនេះត្រូវបានផ្តួចផ្តើមដោយក្រុមហ៊ុន Facebook ដែលមានជំនួយពីក្រុមអ្នកជំនាញ ហើយបានរួមបញ្ចូលគំរូចំនួន៤សម្រាប់ជួយបណ្តុះបណ្តាលអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតដើម្បីអភិវឌ្ឍជំនាញ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលប្រកបដោយសុវត្ថិភាព និងទំនួលខុសត្រូវ។

ខណៈពេលពិភពលោកកំពុងឆ្ពោះទៅរកបដិវត្តន៍ឧស្សាហកម្មទី៤ កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីសម្របខ្លួនទៅនឹងបម្រែបម្រួលបរិស្ថានឌីជីថល និងភាពជឿនលឿនផ្នែកបច្ចេកវិទ្យានេះដូចគ្នា ដើម្បីសម្រេចកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ខ្លួន។ ជាក់ស្តែង នាយករដ្ឋមន្ត្រីកម្ពុជា បានណែនាំឲ្យឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បង្កើតក្រុមការងារជំនាញ ដើម្បីធ្វើការប្រមូលធាតុផ្សំក្នុងការបង្កើតក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល ដែលត្រូវរួមបញ្ចូលការលើកកម្ពស់អក្ខរកម្មឌីជីថលទៅក្នុងក្របខណ្ឌទាំងមូល (Office of the Council of Ministers, 2019)។ ចំពោះវិស័យអប់រំវិញ ក្រសួងអប់រំ យុវជន និងកីឡារបស់ព្រះរាជាណាចក្រកម្ពុជា បានធ្វើការសហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (ហៅកាត់ថា KAPE) និងគំនិតផ្តួចផ្តើម ធនធានសិក្សា (TTS) ដើម្បីអនុវត្ត និងពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មី ក្នុងគោលដៅលើកកម្ពស់ស្តង់ដារអប់រំផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Voun, 2019)។ ជាមួយគ្នានេះដែរ កម្មវិធីសាលារៀនជំនាន់ថ្មី ក៏បានដាក់បញ្ចូលមធ្យោបាយរៀនបែបឌីជីថល រួមមាន ការប្រើប្រាស់កម្មវិធីកុំព្យូទ័រ និងកម្មវិធីទូរស័ព្ទនៅក្នុងថ្នាក់រៀន ក្រោមការជួយជ្រោមជ្រែងពីក្រុមហ៊ុន Microsoft (Voun, 2019)។

ទោះជាយ៉ាងនេះក្តី កម្ពុជាដែលជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប មានការងារត្រូវធ្វើ និងបញ្ហាត្រូវដោះស្រាយជាច្រើនទៀត ដើម្បីធ្វើការផ្លាស់ប្តូរឲ្យក្លាយជាសង្គមឌីជីថលពេញលេញមួយ។ បញ្ហាប្រឈមភាគច្រើន គឺទាក់ទងនឹងធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធឌីជីថល អភិបាលកិច្ច និងការច្នៃប្រឌិតឌីជីថល។ លើសពីនេះ កម្ពុជាកំពុងដើរយឺតជាងបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់នៅឡើយ ទាក់ទងនឹងវិស័យឌីជីថល។ ជាក់ស្តែង អាត្រាកំណើនការប្រើប្រាស់ និងការជ្រៀតចូលក្នុងប្រព័ន្ធ អ៊ីនធឺណិតនៅកម្ពុជាមានត្រឹមតែ ១២ភាគរយប៉ុណ្ណោះ ធៀបនឹងវៀតណាម ២៨ភាគរយ និងមីយ៉ាន់ម៉ា ២៩ភាគរយ។ មួយវិញទៀត អក្ខរកម្ម និងជំនាញឌីជីថលនៅមានកម្រិតទាប ដែលបានជះឥទ្ធិពលអវិជ្ជមានដល់ទីផ្សារការងារនៅកម្ពុជា (Heng, 2019)។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ និងសម្រេចបានការផ្លាស់ប្តូរឌីជីថលពេញលេញមួយ កម្ពុជាចាំបាច់ត្រូវមានផែនការយុទ្ធសាស្ត្ររយៈពេលវែងនៅក្នុងវិស័យសំខាន់ៗ ដូចជាវិស័យអប់រំ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងក្របខណ្ឌច្បាប់ក្នុងការគ្រប់គ្រង។

កម្ពុជា បាន និងកំពុងជំរុញសន្ទុះនៃការត្រៀមខ្លួនចំពោះបញ្ហាប្រឈម និងការចាប់យកឱកាសពីឧស្សាហកម្ម៤.០។ ខណៈពេលដែលមានការខិតខំប្រឹងប្រែងអភិវឌ្ឍវិស័យឌីជីថល តួនាទីរបស់អក្ខរកម្មឌីជីថល ត្រូវតែមានការទទួលស្គាល់ព្រោះវាជាផ្នែកសំខាន់មួយក្នុងការកសាងសេដ្ឋកិច្ច និងសង្គមបែបឌីជីថល។ ទន្ទឹមនឹងនេះ ការលើកកម្ពស់អក្ខរកម្ម និងជំនាញឌីជីថលត្រូវមានការជម្រុញ និងលើកទឹកចិត្តដើម្បីឲ្យប្រជាពលរដ្ឋកម្ពុជា ទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាក្នុងបរិបទសេដ្ឋកិច្ចឌីជីថល និងឧស្សាហកម្ម ៤.០។

## ឯកសារយោង

Angeles, S. (2014, April 25). Five tech skills every worker needs. *Business News Daily*. Retrieved from https://www.businessnewsdaily.com/6316-tech-skills-job-seeker.html

Basu Das, S. (2018, February 6). Asean needs to fix its digital divide. *The Straits Times*. Retrieved from https://www.straitstimes.com/opinion/asean-needs-to-fix-its-digital-divide

Bawden, D. (2008). Origins and concepts of digital literacy. In *Digital literacy: Concepts, policies and practices* (pp. 18-19). Lankshear and Knobel.

ChannelNews Asia. (2019, May 5). *Singapore first port of call in Asia Pacific for Facebook's new digital literacy initiative*. Retrieved from https://www.channelnewsasia.com/news/technology/singapore-first-country-asia-pacific-facebook-digital-literacy-11312828

Deloitte. (n.d.). *What is digital economy: Unicorns, transformation, and the internet of things.* Retrieved from https://www2.deloitte.com/mt/en/pages/technology/articles/mt-what-is-digital-economy.html

Department of eLeaning. (n.d.). 21st Century Competencies for Our Age: The Digital Age. In *Green Paper: Digital Literacy (pp* 8-10). Malta: Ministry for Education and Employment.

e-Estonia. (n.d.). *Success stories*. Retrieved from https://e-estonia.com/

Luo, C. (2016, May 16). *The ASEAN Digital Revolution*. A.T. Kearney. Retrieved from https://www.atkearney.com/documents/10192/7567195/ASEAN+Digital+Revolution.pdf/86c51659-c7fb-4bc5-b6e1-22be3d801ad2

Mansel, T. (2013, May 16). How Estonia became E-Stonia. *BBC News*. Retrieved from https://www.bbc.com/news/business-22317297

Office of the Council of Ministers. *Selected Comments Samdech Techo Hun Sen, at the 2019 Cambodia Outlook Conference: Partnership between Cambodia Development Research Institute (CDRI) and G Gear under the Theme: "Digital Transformation Towards Industry 4.0" [Unofficial Translation]*. (2019, March 26). Retrieved from https://pressocm.gov.kh/en/archives/50895

Paul, C. M., Kerkshoff, S., & Spires, H. (2017). Digital Literacy for the 21st Century. In *Encyclopedia of Information Science and Technology* (4th ed.). (pp. 2235-2237). USA: IGI Global.

Sagar, M. (2019, January 17). Thailand pushes for ASEAN Digital Integration Framework Action Plan. *OpenGov Asia*. Retrieved from https://www.opengovasia.com/thailand-pushes-for-asean-digital-integration-framework-action-plan/

The European Commission. (2019, June 12). *The Digital Economy and Society 2018 – Country Report Estonia*. Retrieved from https://ec.europa.eu/digital-single-market/en/desi

Tortermvasana, K. (2018, December 24). Ministry eyes digital skills for 4 million. *Bangkok Post.* Retrieved from https://www.bangkokpost.com/business/1599730/ministry-eyes-digital-skills-for-4-million

Voun, D. (2019, March 01). Minister of Education meets with Microsoft. *The Phnom Penh Post.* Retrieved from https://www.phnompenhpost.com/national/minister-education-meets-microsoft

Wu, D. (2019, May 3). ASEAN must embrace digitisation for development. *East Asia Forum*. Retrieved from https://www.eastasiaforum.org/2019/05/03/asean-must-embrace-digitisation-for-development/

Cambodia Development Center

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | (+855) 10 950 456

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center